# អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបអំពើ
# ភេរវកម្មនុយក្លេអ៊ែរ

អង្គការសហប្រជាជាតិ

2005

## **អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបអំពើភេរវកម្មនុយក្លេអ៊ែរ**

*រដ្ឋភាគីចំពោះអនុសញ្ញានេះ*

*ដោយផ្អែកលើ*គោលបំណង និងគោលការណ៍ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិស្តីពីការថែទាំសន្តិភាព និងសន្តិសុខអន្តរជាតិ និងការលើកកម្ពស់ភាពជាអ្នកជិតខាងល្អ និងទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋនានា។

*ដោយរំលឹកនូវ*សេចក្តីប្រកាសនៅឱកាសខួបលើកទី១៥របស់អង្គការសហប្រជាជាតិនៅថ្ងៃទី 24 ខែតុលា ឆ្នាំ 1995,

*ដោយទទួលស្គាល់*សិទ្ធិរបស់រដ្ឋភាគីទាំងអស់ក្នុងការអភិវឌ្ឍ និងប្រើប្រាស់ថាមពលនុយក្លេអ៊ែរក្នុងគោលបំណងសន្តិភាព និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួននៅក្នុងអត្ថប្រយោជន៍ជាសក្តានុពលដែលបានកើតចេញពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរប្រកបដោយសន្តិភាព។

*ដោយយោងលើ*អនុសញ្ញាស្តីពីការការពាររូបសាស្ត្រនៃរូបធាតុនុយក្លេអ៊ែរនៅឆ្នាំ 1980,

*ដោយមានការព្រួយបារម្ភយ៉ាងជ្រាលជ្រៅ*អំពីការរីករាលដាលទូទាំងពិភពលោកនូវអំពើភេរវ

កម្មគ្រប់ទម្រង់ និងរូបភាព

*ដោយរំលឹកដល់*សេចក្តីប្រកាសស្តីពីវិធានការលប់បំបាត់ភេរវកម្មអន្តរជាតិដែលបានបញ្ចូលជាឧបសម្ព័ន្ធចំពោះដំណោះស្រាយរបស់អង្គមហាសន្និបាតលេខ 49/60 នៅថ្ងៃទី 9 ខែធ្នូ ឆ្នាំ 1994, ដែលលើសពីនេះទៀតរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិបានអះអាងឡើងវិញជាឱឡារិកនូវការថ្កោលទោសជាដាច់ខាតរបស់ខ្លួនចំពោះអំពើ វិធីសាស្រ្ត និងការអនុវត្តភេរវកម្មថាជាបទឧក្រិដ្ឋ និងមិនអាចអន់ឱនបានចំពោះអំពើដែលបានប្រព្រឹត្តនៅទីណា និងដោយនរណាក៏ដោយដែលរួមមានទីកន្លែង និងជនដែលធ្វើឲ្យខូចខាតដល់ទំនាក់ទំនងជាមិត្តភាពនៅក្នុងចំណោមរដ្ឋនានា និងប្រជាជន និងគំរាមកំហែងដល់បូរណភាពទឹកដី និងសន្តិសុខរបស់រដ្ឋនានា

*ដោយកត់សម្គាល់*ថាសេចក្តីប្រកាសនេះក៏បានលើកទឹកចិត្តរដ្ឋនានាឲ្យពិនិត្យមើលឡើងវិញជាបន្ទាន់នូវវិសាលភាពនៃមាត្រានីតិអន្តរជាតិដែលមានស្រាប់ស្តីពីការបង្ការ ទប់ស្កាត់ និងលប់បំបាត់ភេរវកម្មនៅគ្រប់ទម្រង់និងរូបភាពទាំងអស់ ក្នុងគោលបំណងដើម្បីធានាថាមានក្របខណ្ឌច្បាប់ទូលំទូលាយដែលគ្របដណ្តប់លើទិដ្ឋភាពបញ្ហាទាំងអស់។

ដោយរំលឹកពីដំណោះស្រាយរបស់អង្គមហាសន្និបាតលេខ 51/210 ចុះថ្ងៃទី 17 ខែធ្នូ ឆ្នាំ 1996 និងសេចក្តីប្រកាសបំពេញបន្ថែមលើសេចក្តីប្រកាសឆ្នាំ 1994 ស្តីពីវិធានការលុបបំបាត់ភេរវកម្មអន្តរជាតិដែលបានដាក់បញ្ចូលជាឧបសម្ព័ន្ធចំពោះសេចក្តីប្រកាសនោះ

*ដោយរំលឹកផងដែរ*ថាដោយអនុលោមទៅតាមដំណោះស្រាយរបស់អង្គមហាសន្និបាទលេខ 51/210, គណៈកម្មការពិសេសត្រូវបានបង្កើតឡើងដើម្បីបកស្រាយអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបអំពើភេរវកម្មនុយក្លេអ៊ែរដើម្បីបំពេញបន្ថែមលើលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធដែលមានស្រាប់។

*ដោយកត់សម្គាល់*ថាអំពើភេរវកម្មនុយក្លេអ៊ែរអាចបណ្តាលឲ្យមានផលវិបាកធ្ងន់ធ្ងរបំផុត និងអាចបង្កការគំរាមកំហែងដល់សន្តិសុខ និងសន្តិភាពអន្តរជាតិ

*ដោយកត់សម្គាល់ផងដែរ*ថាមាត្រាច្បាប់ពហុភាគីដែលមានស្រាប់មិនថ្លែងបញ្ជាក់ឲ្យបានគ្រប់គ្រាន់ចំពោះការវាយប្រហារទាំងនោះ

*ដោយជឿជាក់ចំពោះ*តម្រូវការបន្ទាន់ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិរវាងរដ្ឋនានានៅក្នុងការបង្កើត និងទទួលយកវិធានការជាក់ស្តែងនិងមានប្រសិទ្ធភាពសម្រាប់ការបង្ការអំពើភេរវកម្មទាំងនេះ និងសម្រាប់កាត់ទោស និងពិន័យចំពោះអ្នកប្រព្រឹត្ត

*ដោយកត់សម្គាល់*ឃើញថាសកម្មភាពកងកម្លាំងយោធារបស់រដ្ឋនានាត្រូវបានគ្រប់គ្រងដោយក្រមនីតិអន្តរជាតិដែលស្ថិតនៅក្រៅក្របខណ្ឌនៃអនុសញ្ញានេះ និងថាការលើកលែងចំពោះសកម្មភាពមួយចំនួនពីការគ្របដណ្តប់នៃអនុសញ្ញានេះមិនលើកលែងទោសចំពោះអំពើខុសច្បាប់ ឬហាមឃាត់ការកាត់ទោសនៅក្រោមច្បាប់ផ្សេងទៀត

*បានព្រមព្រៀងដូចតទៅ៖*

**មាត្រា 1**

សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖

1. “រូបធាតុវិទ្យុសកម្ម” មានន័យថាជារូបធាតុនុយក្លេអ៊ែរ និងសារធាតុវិទ្យុសកម្មដទៃទៀតដែលមានផ្ទុកសារធាតុនុយក្លីតដែលបំបែកធាតុដោយឯកឯង (ជាដំណើរការមួយដែលកើតឡើងព្រមគ្នាដោយការបញ្ចេញរស្មីអ៊ីយ៉ុងមួយ ឬច្រើនប្រភេទដូចជាភាគល្អិតអាល់ហ្វា បែតា ណឺត្រុង និងកាំរស្មីហ្គាំម៉ាជាដើម) និងដែលផ្អែកលើលក្ខណៈវិទ្យុវិទ្យា និងហ្វូស៊ីរបស់វាអាចបណ្តាលឲ្យស្លាប់ រងរបួសរាងកាយធ្ងន់ធ្ងរ ឬខូចខាតដល់ទ្រព្យសម្បត្តិ ឬបរិស្ថានយ៉ាងធ្ងន់ធ្ងរ។

2. “រូបធាតុនុយក្លេអ៊ែរ” គឺជាជាតិព្លុយតូញ៉ូម លើកលែងតែជាតិព្លុយតូញ៉ូមដែលមានកំហាប់អ៊ីសូតូបលើសពី 80 ភាគរយនៅក្នុងធាតុព្លុយតូញ៉ូម-238; អ៊ុយរ៉ាញ៉ូម-233; អ៊ុយរ៉ាញ៉ូមដែលចម្រាញ់នៅក្នុងអ៊ីសូតូប 235 ឬ 233; អ៊ុយរ៉ាញ៉ូមដែលមានល្បាយអ៊ីសូតូបដែលកើតឡើងក្នុងធម្មជាតិក្រៅពីទម្រង់រ៉ែ ឬសំណល់រ៉ែ ឬរូបធាតុដទៃទៀតដែលមានផ្ទុកនូវធាតុខាងដើមមួយ ឬច្រើន

ដែលថា “អ៊ុយរ៉ាញ៉ូមដែលចម្រាញ់នៅក្នុងអ៊ីសូតូប 235 ឬ 233” មានន័យថាអ៊ុយរ៉ាញ៉ូមដែលមានធាតុអ៊ីសូតូប 235 ឬ 233 ឬទាំងពីរនៅក្នុងបរិមាណមួយដែលអត្រាដ៏ច្រើននៃអ៊ីសូតូបទាំងនេះទៅដល់អ៊ីសូតូប 238 គឺធំជាងអត្រាអ៊ីស៊ូតូប 235 រហូតដល់អ៊ីសូតូប 238 ដែលកើតឡើងក្នុងធម្មជាតិ។

3. “គ្រឿងបរិក្ខារនុយក្លេអ៊ែរ” មានន័យថា៖

(a) រ៉េអាក់ទ័រនុយក្លេអ៊ែរទាំងឡាយដែលរួមមានរ៉េអាក់ទ័រដែលដំឡើងនៅលើនាវា រថយន្ត យន្តហោះ ឬវត្ថុអាវកាសសម្រាប់ប្រើប្រាស់ជាប្រភពថាមពលដើម្បីផ្តល់ថាមពល់ដល់នាវា រថយន្ត យន្តហោះ ឬវត្ថុអាវកាសទាំងនេះ ឬសម្រាប់គោលបំណងផ្សេងទៀត

(b) រោងចក្រ ឬគ្រឿងដឹកជញ្ជូនទាំងឡាយដែលប្រើសម្រាប់ផលិត រក្សាទុក កែច្នៃ ឬដឹកជញ្ជូនរូបធាតុវិទ្យុសកម្ម។

4. “ឧបករណ៍” មានន័យថា៖

(a) ឧបករណ៍បំផ្ទុះនុយក្លេអ៊ែរ ឬ

(b) ឧបករណ៍បំបែករូបធាតុវិទ្យុសកម្ម ឬឧបករណ៍បញ្ចេញកាំរស្មីដែលផ្អែកលើលក្ខណៈវិទ្យុវិទ្យារបស់វាអាចបណ្តាលឲ្យស្លាប់ រងរបួសរាងកាយធ្ងន់ធ្ងរ ឬខូចខាតទ្រព្យសម្បត្តិ ឬបរិស្ថានយ៉ាងធ្ងន់ធ្ងរ។

5. “គ្រឿងបរិក្ខាររដ្ឋ ឬរដ្ឋាភិបាល” រួមមានគ្រឿងបរិក្ខារ ឬគ្រឿងដឹកជញ្ជូនអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នទាំងឡាយណាដែលប្រើ ឬកាន់កាប់ដោយតំណាងរបស់រដ្ឋមួយ ឬសមាជិករបស់រដ្ឋាភិបាលមួយ អង្គនីតិបញ្ញត្តិ ឬថៅក្រម ឬដោយមន្ត្រី ឬបុគ្គលិករបស់រដ្ឋមួយ ឬអាជ្ញាធរសាធារណៈដទៃទៀត ឬអង្គភាព ឬដោយបុគ្គលិក ឬមន្ត្រីរបស់អង្គភាពរដ្ឋាភិបាលមួយដែលពាក់ព័ន្ធនឹងកាតព្វកិច្ចផ្លូវការរបស់ពួកគេ។

6. “កងកម្លាំងយោធារបស់រដ្ឋមួយ” មានន័យថាជាកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋមួយដែលត្រូវបានរៀបចំ បណ្តុះបណ្តាល និងបំពាក់អាវុធនៅក្រោមច្បាប់ផ្ទៃក្នុងរបស់ខ្លួនក្នុងគោលបំណងចម្បងដើម្បីការពារ ឬសន្តិសុខជាតិ និងមនុស្សដែលដើរតួគាំទ្រកងកម្លាំងប្រដាប់អាវុធទាំងនោះដែលស្ថិតនៅក្រោមការបញ្ជា ការគ្រប់គ្រង និងការទទួលខុសត្រូវផ្លូវការរបស់ខ្លួន។

## មាត្រា 2

1. បុគ្គលណាម្នាក់ប្រព្រឹត្តិបទល្មើសនៅក្នុងខ្លឹមសារនៃអនុសញ្ញានេះ ប្រសិនបើបុគ្គលនោះប្រព្រឹត្តិដោយខុសច្បាប់ និងដោយចេតនា៖

(a) កាន់កាប់រូបធាតុវិទ្យុសកម្ម ឬផលិត ឬកាន់កាប់ឧបករណ៍៖

(i) ក្នុងចេតនាដើម្បីសម្លាប់ ឬបង្ករបួសរាងកាយធ្ងន់ធ្ងរ ឬ

(ii) ក្នុងចេតនាដើម្បីធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិ ឬបរិស្ថានធ្ងន់ធ្ងរ

(b) ប្រើប្រាស់រូបធាតុវិទ្យុសកម្ម ឬឧបករណ៍តាមរបៀបណាមួយ ឬប្រើប្រាស់ ឬបង្កការខូចខាតគ្រឿងបរិក្ខារនុយក្លេអ៊ែរតាមរបៀបមួយដែលបញ្ចេញ ឬបង្កហានិភ័យនៃការបញ្ចេញសារធាតុវិទ្យុសកម្ម៖

(i) ក្នុងចេតនាដើម្បីសម្លាប់ ឬបង្ករបួសរាងកាយធ្ងន់ធ្ងរ។

(ii) ក្នុងចេតនាដើម្បីធ្វើឲ្យខូចខាតដល់ទ្រព្យសម្បត្តិ ឬបរិស្ថានធ្ងន់ធ្ងរ ឬ

(iii) ក្នុងចេតនាដើម្បីបង្ខិតបង្ខំឲ្យនីតិបុគ្គល ឬរូបវ័ន្តបុគ្គល អង្គការអន្តរជាតិ ឬរដ្ឋមួយធ្វើ ឬមិនធ្វើសកម្មភាពណាមួយ។

2. លើសពីនេះទៀត បុគ្គលណាម្នាក់ប្រព្រឹត្តបទល្មើស ប្រសិនបើបុគ្គលនោះ៖

(a) គំរាមកំហែងនៅក្រោមកាលៈទេសៈដែលបង្ហាញភាពដែលអាចជឿជាក់បាននៃការគំរាមកំហែង ដើម្បីប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងកថាខណ្ឌ 1 (*b*) នៃមាត្រាបច្ចុប្បន្ន ឬ

(b) ទាមទារដោយខុសច្បាប់ និងដោយចេតនានូវរូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរតាមការគំរាមកំហែង នៅក្រោមកាលៈទេសៈដែលបង្ហាញភាពដែលអាចជឿជាក់បាននៃការគំរាមកំហែង ដើម្បីប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងកថាខណ្ឌ 1 (*b*) នៃមាត្រាបច្ចុប្បនៃការគំរាមកំហែង ឬតាមរយៈការប្រើប្រាស់កម្លាំង។

3. លើសពីនេះទៀត បុគ្គលណាម្នាក់ប្រព្រឹត្តបទល្មើស ប្រសិនបើបុគ្គលនោះប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងកថាខណ្ឌ 1 នៃមាត្រាបច្ចុប្បន្ន។

4. លើសពីនេះទៀត បុគ្គលណាម្នាក់ប្រព្រឹត្តបទល្មើស ប្រសិនបើបុគ្គលនោះ៖

(a) ចូលរួមជាអ្នកសមគំនិតក្នុងបទល្មើសដូចមានចែងនៅក្នុងកថាខណ្ឌ 1, 2 ឬ 3 នៃមាត្រាបច្ចុប្បន្ន ឬ

(b) រៀបចំ ឬដឹកនាំអ្នកផ្សេងឲ្យប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងកថាខណ្ឌ 1, 2 ឬ 3 នៃមាត្រាបច្ចុប្បន្ន ឬ

(c) រួមចំណែកក្នុងការប្រព្រឹត្តបទល្មើសមួយ ឬច្រើនតាមរបៀបផ្សេងដូចមានចែងនៅក្នុងកថាខណ្ឌ 1, 2 ឬ 3 នៃមាត្រាបច្ចុប្បន្នដោយមនុស្សមួយក្រុមដែលប្រព្រឹត្តក្នុងគោលបំណងរួមគ្នា ការរួមចំណែកបែបនេះនឹងប្រកបដោយចេតនា និងអាចធ្វើឡើងក្នុងគោលបំណងបង្កើនសកម្មភាពឧក្រិដ្ឋទូទៅ ឬគោលបំណងរបស់ក្រុម ឬត្រូវបានធ្វើឡើងដោយដឹងពីចេតនារបស់ក្រុមក្នុងការប្រព្រឹត្តបទល្មើស ឬបទល្មើសពាក់ព័ន្ធ។

## មាត្រា 3

អនុសញ្ញានេះមិនត្រូវអនុវត្តនៅកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងរដ្ឋតែមួយ ជនល្មើសដែលបានចោទប្រកាន់ និងជនរងគ្រោះគឺជាពលរដ្ឋរបស់រដ្ឋនោះ ជនល្មើសត្រូវបានចាប់ខ្លួននៅក្នុងទឹកដីនៃរដ្ឋនោះ ហើយរដ្ឋផ្សេងមិនមានមូលដ្ឋាននៅក្រោមមាត្រា 9, កថាខណ្ឌ 1 ឬ 2 ក្នុងការនុវត្តយុត្តាធិការ លើកលែងតែថាខចែងនៃមាត្រា 7, 12, 14, 15, 16 និង 17 ត្រូវអនុវត្តនៅក្នុងករណីទាំងនោះ តាមការគួរ។

## មាត្រា 4

1. មិនមានចំណុចណាមួយនៅក្នុងអនុសញ្ញានេះប៉ះពាល់ដល់សិទ្ធិ កាតព្វកិច្ច និងទំនួលខុសត្រូវដទៃទៀតរបស់រដ្ឋ និងបុគ្គលទាំងឡាយនៅក្រោមនីតិអន្តរជាតិ ជាពិសេសគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងនីតិមនុស្សធម៌អន្តរជាតិឡើយ។

2. សកម្មភាពរបស់កងកម្លាំងប្រដាប់អាវុធនៅអំឡុងពេលមានជម្លោះប្រដាប់អាវុធ ពីព្រោះលក្ខខណ្ឌទាំងនោះត្រូវបានទទួលស្គាល់នៅក្រោមនីតិមនុស្សធម៌អន្តរជាតិ ដែលត្រូវបានគ្រប់គ្រងដោយច្បាប់នោះ មិនត្រូវបានគ្រប់គ្រងដោយអនុសញ្ញានេះទេ ហើយសកម្មភាពនានាដែលធ្វើឡើងដោយកងកម្លាំងយោធារបស់រដ្ឋមួយដើម្បីអនុវត្តកាតព្វកិច្ចផ្លូវការរបស់ខ្លួន ដោយហេតុថាពួកវាត្រូវបានគ្រប់គ្រងដោយវិធានដទៃទៀតនៃនីតិអន្តរជាតិ មិនត្រូវបានគ្រប់គ្រងដោយអនុសញ្ញានេះឡើយ។

3. ខចែងនៃកថាខណ្ឌ 2 នៃមាត្រាបច្ចុប្បន្នមិនត្រូវបានបកស្រាយថាជាការអត់អោន ឬធ្វើឲ្យមានភាពស្របច្បាប់ដល់អំពើខុសច្បាប់ ឬរារាំងការកាត់ទោសនៅក្រោមច្បាប់ផ្សេងទៀតឡើយ។

4. អនុសញ្ញានេះដោះស្រាយ ឬមិនអាចត្រូវបានបកស្រាយថាជាការដោះស្រាយ តាមរបៀបមួយ ដែលបញ្ហានៃនីតត្យានុកូលភាពនៃការប្រើប្រាស់ ឬការគំរាមប្រើប្រាស់អាវុធនុយក្លេអ៊ែរដោយរដ្ឋ។

## មាត្រា 5

រដ្ឋភាគីនីមួយៗត្រូវទទួលយកវិធានការទាំងនេះនៅពេលមានការចាំបាច់៖

(a) ដើម្បីបង្កើតនៅពេលបទល្មើសឧក្រិដ្ឋនៅក្រោមច្បាប់ជាតិរបស់ខ្លួន បទល្មើសដែលបានចែងនៅក្នុងមាត្រា 2

(b) ដើម្បីអាចដាក់ទោសដល់បទល្មើសទាំងនោះបានតាមការដាក់ពិន័យសមស្របដែលចាត់ទុកបទល្មើសទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ។

## មាត្រា 6

រដ្ឋភាគីនីមួយៗត្រូវទទួលយកវិធានការទាំងនេះតាមការចាំបាច់ ដែលរួមមាន ច្បាប់ក្នុងស្រុកដើម្បីធានាថាអំពើឧក្រិដ្ឋស្ថិតនៅក្នុងវិសាលភាពនៃអនុសញ្ញានេះ ជាពិសេសច្បាប់ទាំងនេះមានចេតនា ឬបង្កើតឡើងដើម្បីបង្កនូវស្ថានភាពភ័យខ្លាចចំពោះសាធារណជនទូទៅ ឬក្រុមមនុស្សមួយក្រុម ឬមនុស្សដោយឡែក មិនស្ថិតនៅក្រោមកាលៈទេសៈដែលអាចបញ្ជាក់ថាត្រឹមត្រូវដោយការពិចារណាអំពីលក្ខណៈនយោបាយ ទស្សនវិទ្យា មនោគមវិទ្យា ពូជសាសន៍ ជាតិសាសន៍ សាសនា ឬលក្ខណៈស្រដៀងគ្នាផ្សេងទៀត និងត្រូវទទួលរងការពិន័យស្របទៅតាមទម្ងន់ទោសរបស់ពួកគេ។

## មាត្រា 7

1. រដ្ឋភាគីត្រូវសហប្រតិបត្តិការតាមរយៈ៖

(a) ការចាត់វិធានការជាក់ស្តែងទាំងអស់ប្រសិនបើចាំបាច់ ដូចជាសម្របទៅតាមច្បាប់ជាតិរបស់ខ្លួន ដើម្បីបង្ការ និងប្រឆាំងការរៀបចំនៅក្នុងទឹកដីរៀងៗខ្លួនសម្រាប់ការប្រព្រឹត្តិនៅក្នុង ឬខាងក្រៅទឹកដីរបស់ខ្លួនដែលមានបទល្មើស ដែលបានចែងនៅក្នុងមាត្រា 2, ដោយរួមមានវិធានការហាមឃាត់នៅក្នុងទឹកដីរបស់ខ្លួននូវសកម្មភាពខុសច្បាប់របស់មនុស្ស ក្រុម និងអង្គការនានាដែលលើកទឹកចិត្ត ពន្យុះ រៀបចំ ផ្តល់ហរិញ្ញវត្ថុ ឬផ្តល់ជំនួយបច្ចេកទេសដោយចេតនា ឬព័ត៌មាន ឬពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តបទល្មើសទាំងនោះ

(b) ការដោះដូរព័ត៌មានត្រឹមត្រូវនិងមានការផ្ទៀងផ្ទាត់ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន និងតាមរបៀប និងស្ថិតនៅក្នុងលក្ខខណ្ឌដែលបានបញ្ជាក់ច្បាស់នៅទីនេះ និងការសម្របសម្រួលវិធានការរដ្ឋបាល និងវិធានការដទៃទៀតដែលបានអនុវត្តឡើងសមស្របដើម្បីរកមុខ បង្ការ ទប់ស្កាត់ និងស៊ើបអង្កេតបទល្មើសនានាដែលមានចែងនៅក្នុងមាត្រា 2 និងលើសពីនេះទៀតដើម្បីបង្កើតកិច្ចនីតិវិធីឧក្រិដ្ឋប្រឆាំងនឹងបុគ្គលដែលគេចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ ដោយឡែក រដ្ឋភាគីមួយត្រូវចាត់វិធានការសមស្របដើម្បីជូនព័ត៌មានភ្លាមៗដល់រដ្ឋផ្សេងទៀតដែលមានចែងនៅក្នុងមាត្រា 9 ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងមាត្រា 2 និងការរៀបចំដើម្បីប្រព្រឹត្តបទល្មើសដែលខ្លួនបានដឹង និងលើសពីនេះទៀតត្រូវជូនដំណឹងដល់អង្គការអន្តរជាតិនានាតាមចាំបាច់។

2. រដ្ឋភាគីនានាត្រូវចាត់វិធានការសមស្របដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួនដើម្បីបង្ការភាពសម្ងាត់នៃព័ត៌មានដែលខ្លួនទទួលជាសម្ងាត់តាមមាត្រានៃអនុសញ្ញានេះពី

រដ្ឋភាគីមួយទៀត ឬតាមរយៈការចូលរួមនៅក្នុងសកម្មភាពមួយដែលរៀបចំឡើងសម្រាប់ការអនុវត្តអនុសញ្ញានេះ។ ប្រសិនបើរដ្ឋភាគីផ្តល់ព័ត៌មានដល់អង្គការអន្តរជាតិជាសម្ងាត់ នោះគេត្រូវតែចាត់វិធានការដើម្បីធានាការពារភាពសម្ងាត់នៃព័ត៌មាននេះ។

3. អនុសញ្ញានេះមិនត្រូវតម្រូវឲ្យរដ្ឋភាគីទាំងឡាយផ្តល់ព័ត៌មានណាមួយដែលមិនអនុញ្ញាតឲ្យបង្ហាញព័ត៌មានទាំងនេះទៅតាមច្បាប់ជាតិ ឬដែលបង្កគ្រោះថ្នាក់ដល់សន្តិសុខរបស់រដ្ឋពាក់ព័ន្ធ ឬការការពាររូបសាស្ត្រនៃរូបធាតុនុយក្លេអ៊ែរ។

4. រដ្ឋភាគីត្រូវជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិអំពីអាជ្ញាធរមានសមត្ថកិច្ច និងចំណុចសម្ព័ន្ធការរបស់ខ្លួនដែលទទួលខុសត្រូវក្នុងការផ្ញើ និងទទួលព័ត៌មានដោយយោងទៅតាមមាត្រាបច្ចុប្បន្ន។ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបង្ហាញព័ត៌មានដែលពាក់ព័ន្ធនឹងអាជ្ញាធរមានសមត្ថកិច្ច និងចំណុចសម្ព័ន្ធការដល់រដ្ឋភាគីទាំងអស់ និងទីភ្នាក់ងារថាមពលបរិមាណូអន្តរជាតិ។ អាជ្ញាធរ និងចំណុសម្ព័ន្ធការទាំងនេះត្រូវតែអាចទាក់ទងបានជាបន្តបន្ទាប់។

## មាត្រា 8

សម្រាប់គោលបំណងបង្ការបទល្មើសនៅក្រោមអនុសញ្ញានេះ រដ្ឋភាគីត្រូវខិតខំប្រឹងប្រែងគ្រប់យ៉ាងដើម្បីទទួលយកវិធានការសមស្របដើម្បីធានាបង្ការរូបធាតុវិទ្យុសកម្ម ដោយពិចារណាអំពីអនុសាសន៍ពាក់ព័ន្ធ និងមុខងាររបស់ទីភ្នាក់ងារថាមពលបរិមាណូអន្តរជាតិ។

## មាត្រា 9

1. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការទាំងនេះតាមចាំបាច់ដើម្បីបង្កើតយុត្តាធិការលើបទល្មើសដែលមានចែងនៅក្នុងមាត្រា 2 នៅពេល៖

(a) បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីនៃរដ្ឋនោះ ឬ

(b) បទល្មើសត្រូវបានប្រព្រឹត្តនៅលើនាវាដែលដោតទង់ជាតិនៃរដ្ឋនោះ ឬយន្តហោះដែលបានចុះបញ្ជីនៅក្រោមច្បាប់នៃរដ្ឋនោះនៅពេលបទល្មើសត្រូវបានប្រព្រឹត្ត ឬ

(c) បទល្មើសត្រូវបានប្រព្រឹត្តដោយពលរដ្ឋនៃរដ្ឋនោះ។

2. រដ្ឋភាគីក៏អាចបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសណាមួយនៅពេល៖

(a) បទល្មើសត្រូវបានប្រព្រឹត្តប្រឆាំងនឹងពលរដ្ឋនៃរដ្ឋនោះ ឬ

(b) បទល្មើសត្រូវបានប្រព្រឹត្តប្រឆាំងនឹងអគាររដ្ឋ ឬរដ្ឋាភិបាលនៃរដ្ឋនោះដែលស្ថិតនៅបរទេស ដូចជាស្ថានទូត ឬបរិវេណរដ្ឋទូត ឬស្ថានកុងស៊ុលដទៃទៀតរបស់រដ្ឋនោះ ឬ

(c) បទល្មើសត្រូវបានប្រព្រឹត្តដោយបុគ្គលគ្មានរដ្ឋដែលមាននិវេសនដ្ឋានរបស់ខ្លួននៅក្នុងទឹកដីនៃរដ្ឋនោះ ឬ

(d) បទល្មើសត្រូវបានប្រព្រឹត្តដើម្បីប៉ុនប៉ងបង្ខិតបង្ខំរដ្ឋនោះឲ្យធ្វើ ឬអនុប្បវាទពីការធ្វើសកម្មភាពណាមួយ ឬ

(e) បទល្មើសត្រូវបានប្រព្រឹត្តនៅលើយន្តហោះដែលប្រតិបត្តិការដោយរដ្ឋាភិបាលនៃរដ្ឋនោះ។

3. នៅពេលផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬយល់ព្រមចំពោះអនុសញ្ញានេះ រដ្ឋភាគីនីមួយៗត្រូវជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិអំពីយុត្តាធិការដែលខ្លួនបានបង្កើតឡើងនៅក្រោមច្បាប់ជាតិរបស់ខ្លួនដោយអនុលោមតាមកថាខណ្ឌ 2 នៃមាត្រាបច្ចុប្បន្ន។ ប្រសិនបើមានការកែប្រែ រដ្ឋភាគីដែលពាក់ព័ន្ធត្រូវជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិជាបន្ទាន់។

4. ដូច្នោះដែរ រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការទាំងនេះតាមចាំបាច់ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសដែលបានចែងនៅក្នុងមាត្រា 2 ក្នុងករណីដែលជនល្មើសដែលគេចោទប្រកាន់មានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន និងមិនធ្វើបត្យាប័នបុគ្គលនោះទៅកាន់រដ្ឋភាគីណាមួយដែលបានបង្កើតយុត្តាធិការរបស់ខ្លួនស្របទៅតាមកថាខណ្ឌ 1 ឬ 2 នៃមាត្រាបច្ចុប្បន្ន។

5. អនុសញ្ញានេះមិនរាប់បញ្ចូលនូវការអនុវត្តយុត្តាធិការបទឧក្រិដ្ឋណាមួយដែលបានបង្កើតឡើងដោយរដ្ឋភាគីមួយដោយអនុលោមតាមច្បាប់ជាតិឡើយ។

## មាត្រា 10

1. នៅពេលទទួលបានព័ត៌មានដែលបទល្មើសមានចែងនៅក្នុងមាត្រា 2 ត្រូវបានប្រព្រឹត្ត ឬកំពុងត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីនៃរដ្ឋភាគីមួយ ឬថាបុគ្គលដែលបានប្រព្រឹត្ត ឬដែលរងការចោទប្រកាន់ ថាបានប្រព្រឹត្តបទល្មើសនេះអាចមានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន រដ្ឋភាគីដែលពាក់ព័ន្ធត្រូវចាត់វិធានការតាមចាំបាច់ដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួនដើម្បីស៊ើបអង្កេតអង្គហេតុដែលមាននៅក្នុងព័ត៌មាននោះ។

2. នៅពេលយល់ថាកាលៈទេសៈតម្រូវដូច្នេះ រដ្ឋភាគីដែលជនល្មើស ឬជនល្មើសដែលចោទប្រកាន់មានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន ត្រូវចាត់វិធានការសមស្របដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួនដើម្បីធានាថាវត្តមានរបស់បុគ្គលនោះគឺសម្រាប់ការកាត់ទោស ឬការធ្វើបត្យាប័ន។

3. បុគ្គលដែលពាក់ព័ន្ធនឹងវិធានការនេះមានយោងនៅក្នុងកថាខណ្ឌ 2 នៃមាត្រាបច្ចុប្បន្នដែលកំពុងត្រូវបានធ្វើឡើងត្រូវបានចាត់តាំង៖

(a) ដើម្បីផ្តល់ព័ត៌មានដោយគ្មានការពន្យារពេលដោយមានអ្នកតំណាងសមស្របដែលនៅជិតបំផុតនៃរដ្ឋរបស់បុគ្គលនោះ ឬពុំនោះទេត្រូវបានផ្តល់សិទ្ធិឲ្យការពារសិទ្ធិរបស់បុគ្គលនោះ ឬប្រសិនបើបុគ្គលនោះជាមនុស្សគ្មានរដ្ឋ រដ្ឋនៅក្នុងទឹកដីដែលបុគ្គលនោះស្នាក់នៅតាមទម្លាប់

(b) ដើម្បីទទួលការមកដល់របស់តំណាងនៃរដ្ឋនោះ

(c) ដើម្បីទទួលព័ត៌មានអំពីសិទ្ធិរបស់បុគ្គលនោះនៅក្រោមអនុកថាខណ្ឌ (*a*) និង (*b*)។

4. សិទ្ធិដែលបានលើកឡើងនៅក្នុងកថាខណ្ឌ 3 នៃមាត្រាបច្ចុប្បន្នត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋនៅក្នុងទឹកដីដែលជនល្មើស ឬជនល្មើសដែលបានចោទប្រកាន់មានវត្តមានស្ថិតនៅក្រោម

មាត្រាដែលច្បាប់ ឬបទប្បញ្ញត្តិដែលបានលើកឡើងនោះត្រូវតែអាចទទួលបានអនុភាពពេញលេញចំពោះគោលបំណងដែលសិទ្ធិត្រូវបានអនុញ្ញាតដោយអនុលោមតាមកថាខណ្ឌ 3។

5. មាត្រានៃកថាខណ្ឌ 3 និង 4 នៃមាត្រាបច្ចុប្បន្នដោយពុំទាន់គិតដល់សិទ្ធិរបស់រដ្ឋភាគីណាមួយដែលបានទាមទារនូវយុត្តាធិការដោយអនុលោមតាមមាត្រា 9, កថាខណ្ឌ 1 (*c*) ឬ 2 (*c*), ដើម្បីអញ្ជើញគណៈកម្មការអន្តរជាតិកក្កបាទក្រហមធ្វើការទាក់ទងជាមួយ និងទៅសួរសុខទុកជនល្មើសដែលបានចោទប្រកាន់នោះ។

6. ដោយអនុលោមតាមមាត្រាបច្ចុប្បន្ន នៅពេលរដ្ឋភាគីមួយបានចាប់បុគ្គលនោះដាក់ពន្ធនាគារ រដ្ឋនោះត្រូវជូនដំណឹងជាបន្ទាន់ ដោយផ្ទាល់ ឬតាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋភាគីនានាដែលបានបង្កើតយុត្តាធិការស្របនឹងមាត្រា 9 កថាខណ្ឌ 1 និង 2, និងប្រសិនបើរដ្ឋនោះទុកថាវាគួរតែធ្វើឡើង រដ្ឋភាគីដែលមានចំណាប់អារម្មណ៍អំពីអង្គហេតុដែលថាបុគ្គលនោះត្រូវជាប់ពន្ធនាគារ និងកាលៈទេសៈដែលចេញដីការឃុំខ្លួនបុគ្គលនោះ។ រដ្ឋដែលស៊ើបអង្កេតបានពិនិត្យមើលនៅក្នុងកថាខណ្ឌ 1 នៃមាត្រាបច្ចុប្បន្នត្រូវជូនដំណឹងដល់រដ្ឋភាគីទាំងនោះជាបន្ទាន់អំពីការរកឃើញរបស់ខ្លួន និងត្រូវបង្ហាញថាតើខ្លួនមានបំណងអនុវត្តយុត្តាធិការនេះដែរឬទេ។

## **មាត្រា 11**

1. រដ្ឋភាគីនៅក្នុងទឹកដីដែលជនល្មើសដែលបានចោទប្រកាន់មានវត្តមាន ក្នុងករណីអនុវត្តមាត្រា 9, ប្រសិនបើមិនធ្វើបត្យាប័នបុគ្គលនោះទេយ៉ាងណាក៏ដោយ ដោយមិនមានការលើកលែង និងទោះជាបទល្មើសនោះត្រូវបានឬមិនត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីរបស់ខ្លួនក៏ដោយ ត្រូវមានកាតព្វកិច្ច ដាក់បញ្ជូនករណីនេះដោយមិនការពន្យារពេលច្រើនដល់អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីវិនិច្ឆ័យទោស តាមរយៈកិច្ចនីតិវិធីដោយអនុលោមតាមច្បាប់របស់រដ្ឋនោះ។ អាជ្ញាធរទាំងនោះត្រូវធ្វើការសម្រេចតាមរបៀបដូចគ្នាដូចនៅក្នុងករណីនៃបទល្មើលដទៃទៀត ដែលមានទម្ងន់ទោសនៅក្រោមច្បាប់របស់រដ្ឋនោះ។

2. នៅពេលណាដែលរដ្ឋភាគីទទួលបានការអនុញ្ញាតពីច្បាប់ជាតិរបស់ខ្លួនឲ្យធ្វើបត្យាប័ន ឬពុំនោះទេប្រគល់ខ្លួនជនជាតិរបស់ខ្លួនតែនៅពេលលក្ខខណ្ឌដែលបុគ្គលនឹងត្រូវបញ្ជូនទៅកាន់រដ្ឋនោះវិញដើម្បីទទួលទោសដែលបានដាក់បន្ទាប់ពីមានការកាត់ទោស ឬកិច្ចនីតិវិធីដែលការធ្វើបត្យាប័ន ឬការប្រគល់ខ្លួនបុគ្គលនោះត្រូវបានស្វែងរក ហើយរដ្ឋនេះ និងរដ្ឋដែលស្វែងរកការធ្វើបត្យាប័នជននោះព្រមព្រៀងលើជម្រើសនេះ និងលក្ខខណ្ឌផ្សេងទៀតដែលអាចមានលក្ខណៈសមស្រប ការធ្វើបត្យាប័ន ឬការប្រគល់ខ្លួនតាមលក្ខខណ្ឌបែបនេះត្រូវតែមានលក្ខណៈគ្រប់គ្រាន់ដើម្បីបញ្ចេញកាតព្វកិច្ចដែលមានចែងនៅក្នុងកថាខណ្ឌ 1 នៃមាត្រាបច្ចុប្បន្ន។

## **មាត្រា 12**

បុគ្គលដែលត្រូវជាប់ពន្ធនាគារ ឬទាក់ទងនឹងវិធានការដទៃទៀត ឬកិច្ចនីតិវិធីត្រូវបានអនុវត្តដោយអនុលោមតាមអនុសញ្ញានេះនឹងត្រូវធានានូវការប្រព្រឹត្តដោយយុត្តិធម៌ដែលរួមមានការទទួលបានសិទ្ធិគ្រប់យ៉ាង និងការធានាដែលអនុលោមតាមច្បាប់របស់រដ្ឋនោះនៅក្នុងទឹកដីដែល

បុគ្គលនោះមានវត្តមាន និងមាត្រានីតិអន្តរជាតិដែលត្រូវអនុវត្តដែលរួមមាននីតិអន្តរជាតិស្តីពីសិទ្ធិមនុស្សជាដើម។

## មាត្រា 13

1. បទល្មើសដែលបានចែងនៅក្នុងមាត្រា 2 ត្រូវចាត់ទុកបានរាប់បញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័ន នៅក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលមានស្រាប់រវាងភាគីរដ្ឋណាមួយមុននឹងអនុសញ្ញានេះចូលជាធរមាន។ រដ្ឋភាគីដែលដាក់បញ្ចូលបទល្មើសទាំងនេះជាបទល្មើសដែលអាចធ្វើបត្យាប័នបាននៅគ្រប់សន្ធិសញ្ញាបត្យាប័ននឹងត្រូវជម្រះជាបន្តបន្ទាប់រវាងបទល្មើសទាំងនោះ។

2. នៅពេលរដ្ឋភាគីមួយដែលធ្វើបត្យាប័នឲ្យមានលក្ខខណ្ឌស្តីពីអត្ថិភាពនៃសន្ធិសញ្ញាទទួលបានសំណើសុំធ្វើបត្យាប័នពីរដ្ឋភាគីមួយផ្សេងដែលខ្លួនមិនមានសន្ធិសញ្ញាបត្យាប័ន នោះតាមជម្រើសរបស់ខ្លួន រដ្ឋដែលបានស្នើសុំអាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានច្បាប់សម្រាប់ការធ្វើបត្យាប័នស្តីពីបទល្មើសដែលបានចែងនៅក្នុងមាត្រាទី 2។ ការធ្វើបត្យាប័ននឹងស្ថិតនៅក្រោមលក្ខខណ្ឌផ្សេងទៀតដែលចែងដោយច្បាប់របស់រដ្ឋដែលបានស្នើសុំ។

3. រដ្ឋភាគីនានាដែលមិនបង្កើតលក្ខខណ្ឌបត្យាប័នស្តីពីអត្ថិភាពសម្រាប់សន្ធិសញ្ញាមួយត្រូវតែទទួលស្គាល់បទល្មើសនានាដែលបានចែងនៅក្នុងមាត្រា 2 ថាជាបទល្មើសដែលអាចធ្វើបត្យាប័នបានរវាងរដ្ឋទាំងនោះ ដែលស្ថិតនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់របស់រដ្ឋ ដែលបានស្នើសុំធ្វើបត្យាប័ននោះ។

4. ប្រសិនបើចាំបាច់ ត្រូវចាត់ទុកជាបទល្មើសដែលចែងនៅក្នុងមាត្រា 2 សម្រាប់គោលបំណងធ្វើបត្យាប័នរវាងរដ្ឋភាគីនានា ហាក់ដូចជាបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តមិនត្រឹមតែនៅក្នុងកន្លែងដែលបទល្មើសទាំងនោះកើតឡើងទេ ប៉ុន្តែនៅក្នុងទឹកដីនៃរដ្ឋដែលបានបង្កើតយុត្តាធិការស្របតាមមាត្រា 9 កថាខណ្ឌ 1 និង 2 ផងដែរ។

5. មាត្រានៃសន្ធិសញ្ញាបត្យាប័ន និងកិច្ចព្រមព្រៀងទាំងអស់រវាងរដ្ឋភាគីស្តីពីបទល្មើសដែលចែងនៅក្នុងមាត្រា 2 ត្រូវចាត់ទុកថាត្រូវបានកែសម្រួលរវាងរដ្ឋភាគីទៅដល់កម្រិតដែលសន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងនេះមិនត្រូវគ្នាជាមួយអនុសញ្ញានេះ។

## មាត្រា 14

1. រដ្ឋភាគីត្រូវប្រគល់ឲ្យគ្នាទៅវិញទៅមកនូវវិធានការជំនួយដ៏ធំបំផុតដែលទាក់ទងនឹងការស៊ើបអង្កេត ឬកិច្ចនីតិវិធីឧក្រិដ្ឋ ឬបត្យាប័នដែលមានទាក់ទងនឹងបទល្មើសដែលចែងនៅក្នុងមាត្រា 2, ដែលរួមមានជំនួយក្នុងការទទួលបានភ័ស្តុតាងដែលមានសម្រាប់ប្រើប្រាស់តាមចាំបាច់សម្រាប់កិច្ចនីតិវិធី។

2. រដ្ឋភាគីត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមកថាខណ្ឌ 1 នៃមាត្រាបច្ចុប្បន្នដែលអនុលោមតាមសន្ធិសញ្ញាណាមួយ ឬកិច្ចសម្រុះសម្រួលផ្សេងទៀតស្តីពីជំនួយផ្លូវច្បាប់ទៅវិញទៅមកដែលអាចកើតមានរវាងរដ្ឋភាគីនានា។ នៅពេលមិនមានសន្ធិសញ្ញា ឬការៀបចំទាំងនេះ រដ្ឋភាគីនានាត្រូវផ្តល់ជំនួយឲ្យគ្នាទៅវិញទៅមកដោយស្របតាមច្បាប់ជាតិ។

**មាត្រា 15**

ក្នុងនាមជាបទល្មើសនយោបាយ ឬបទល្មើសដែលទាក់ទងនឹងបទល្មើសនយោបាយ ឬបទល្មើសដែលប្រព្រឹត្តក្នុងគោលបំណងនយោបាយ មិនត្រូវចាត់ទុកជាបទល្មើសដែលមានចែងនៅក្នុងមាត្រា 2 ក្នុងគោលបំណងធ្វើបត្យាប័ន ឬជំនួយផ្នែកច្បាប់ទៅវិញទៅមកឡើយ។ ដោយហេតុនេះ សំណើសុំធ្វើបត្យាប័ន ឬជំនួយផ្នែកច្បាប់ទៅវិញទៅមកដោយផ្អែកលើបទល្មើសបែប នេះ មិនអាចបដិសេធបានឡើយដោយឈរលើហេតុផលថាវាពាក់ព័ន្ធនឹងបទល្មើសនយោបាយ ឬបទល្មើសដែលពាក់ព័ន្ធនឹងបទល្មើសនយោបាយ ឬបទល្មើសដែលប្រព្រឹត្តក្នុងគោលបំណង នយោបាយ។

**មាត្រា 16**

គ្មានចំណុចណាមួយនៅក្នុងអនុសញ្ញានេះត្រូវបានបកស្រាយថាជាការដាក់កាតព្វកិច្ចក្នុងការធ្វើបត្យាប័ន ឬផ្តល់ជំនួយផ្លូវច្បាប់ទៅវិញទៅមកឡើយ ប្រសិនបើរដ្ឋភាគីដែលបានស្នើសុំមានហេតុផលរឹងមាំក្នុងការជឿជាក់ថាសំណើសុំធ្វើបត្យាប័នសម្រាប់បទល្មើសដែលមានចែងនៅក្នុងមាត្រា 2 ឬសម្រាប់ជំនួយផ្នែកច្បាប់ទៅវិញទៅមកដែលទាក់ទងនឹងបទល្មើសនេះត្រូវបានធ្វើឡើងក្នុងគោលបំណងកាត់ទោស ឬដាក់ទោសមនុស្សដោយឈរលើហេតុផលពូជសាសន៍ សាសនា សញ្ជាតិ ប្រភពជនជាតិ ឬទស្សនៈនយោបាយ ឬដែលគោរពតាមសំណើនេះនឹងបណ្តាលឲ្យមានការខូចខាតដល់តួនាទីរបស់បុគ្គលនោះសម្រាប់ហេតុផលណាមួយក្នុងចំណោមហេតុផលទាំងនេះ។

**មាត្រា 17**

1. អ្នកដែលកំពុងជាប់ឃុំឃាំង ឬកំពុងអនុវត្តទោសនៅក្នុងទឹកដីនៃរដ្ឋភាគីមួយដែលវត្តមានរបស់ខ្លួនស្ថិតនៅក្នុងរដ្ឋភាគីមួយទៀតត្រូវបានស្នើឡើងក្នុងគោលបំណងផ្តល់សាក្សីកម្ម ការកំណត់អត្តសញ្ញាណ ឬពុំនោះទេផ្តល់ជំនួយក្នុងការទទួលយកភ័ស្តុតាងសម្រាប់ការស៊ើបអង្កេត ឬការកាត់ទោសពីបទល្មើសនៅក្នុងអនុសញ្ញានេះអាចត្រូវបានផ្ទេរ ប្រសិនបើបានឆ្លើយតបតាមលក្ខខណ្ឌខាងក្រោមនេះ៖

(a) បុគ្គលនោះផ្តល់ការយល់ព្រមផ្អែកលើព័ត៌មានដោយសេរី ហើយ

(b) អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទាំងពីព្រមព្រៀង ដោយផ្អែកលើលក្ខខណ្ឌទាំងនេះនៅពេលរដ្ឋទាំងនេះអាចមានលក្ខណៈសមស្រប។

2. សម្រាប់គោលបំណងនៃមាត្រាបច្ចុប្បន្ន៖

(a) រដ្ឋដែលទទួលការផ្ទេរបុគ្គលនេះត្រូវមានសិទ្ធិអំណាច និងកាតព្វកិច្ចរក្សាទុកបុគ្គលដែលគេផ្ទេរមកក្នុងពន្ធនាគារ ពុំនោះទេលុះណាតែត្រូវបានស្នើ ឬអនុញ្ញាតដោយរដ្ឋដែលផ្ទេរបុគ្គលនោះមក

(b) រដ្ឋដែលទទួលការផ្ទេរបុគ្គលនោះត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយមិនបង្អង់ក្នុងការបញ្ជូនបុគ្គលនោះត្រឡប់ទៅកាន់ពន្ធនាគារនៃរដ្ឋដែលបានផ្ទេរបុគ្គលនោះមកដោយបានព្រមព្រៀងគ្នាជាមុន ឬពុំនោះទេបានព្រមព្រៀងគ្នាដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទាំងពីរ។

(c) រដ្ឋដែលទទួលការផ្ទេរបុគ្គលនោះមកមិនត្រូវតម្រូវឲ្យរដ្ឋដែលផ្ទេរបុគ្គលនោះមកចាប់ផ្តើមកិច្ចនីតិវិធីធ្វើបត្យាប័នសម្រាប់ការបញ្ជូនបុគ្គលនោះត្រឡប់មកវិញឡើយ។

(d) បុគ្គលដែលគេផ្ទេរត្រូវទទួលបានឥណទានសម្រាប់សេវាកាត់ទោសដែលត្រូវបានធ្វើឡើងនៅក្នុងរដ្ឋដែលផ្ទេរបុគ្គលនោះមកសម្រាប់ការចំណាយពេលវេលានៅក្នុងពន្ធនាគារនៃរដ្ឋដែលទទួលការផ្ទេរបុគ្គលនោះ។

3. លុះណាតែរដ្ឋភាគីដែលត្រូវផ្ទេរបុគ្គលនោះចេញដោយអនុលោមតាមមាត្រាបច្ចុប្បន្នព្រមព្រៀងដូច្នេះ នោះអ្នកនោះមានសញ្ជាតិអ្វីក៏ដោយ មិនត្រូវបានកាត់ទោស ឬឃុំឃាំង ឬដាក់ឲ្យស្ថិតនៅក្រោមការហាមឃាត់សិទ្ធិផ្ទាល់ខ្លួនរបស់គាត់ផ្សេងទៀតនៅក្នុងទឹកដីនៃរដ្ឋដែលទទួលការផ្ទេរបុគ្គលនោះដែលពាក់ព័ន្ធនឹងអំពើ ឬការផ្តន្ទាទោសមុនការចេញដំណើររបស់បុគ្គលនោះ ពីទឹកដីនៃរដ្ឋដែលបានផ្ទេរបុគ្គលនេះចេញ។

## **មាត្រា 18**

1. នៅពេលរឹបអូស ឬគ្រប់គ្រងរូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរ បន្ទាប់ពីការប្រព្រឹត្តបទល្មើសដែលចែងនៅក្នុងមាត្រា 2, រដ្ឋភាគីដែលមានវត្ថុតាងទាំងនេះត្រូវៈ

(a) ចាត់វិធានការប្រែក្លាយរូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារ នុយក្លេអ៊ែរកុំឲ្យមានគ្រោះថ្នាក់

(b) ធានាថាបានរក្សាទុករូបធាតុនុយក្លេអ៊ែរទាំងឡាយឲ្យស្របតាមវិធានសុវត្ថិភាពរបស់ទីភ្នាក់ងារថាមពលបរិមាណូអន្តរជាតិដែលត្រូវអនុវត្ត និង

(c) គិតអំពីអនុសាសន៍ការពាររូបសាស្ត្រ និងបទដ្ឋានសុខភាព និងសុវត្ថិភាព ដែលបានបោះផ្សាយដោយទីភ្នាក់ងារថាមពលបរិមាណូអន្តរជាតិ។

2. នៅពេលបញ្ចប់កិច្ចនីតិវិធីណាមួយដែលពាក់ព័ន្ធនឹងបទល្មើសដែលចែងនៅក្នុងមាត្រា 2, ឬប្រសិនបើមានការតម្រូវពីនីតិអន្តរជាតិភ្លាម នោះរូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរទាំងឡាយត្រូវតែបញ្ជូនត្រឡប់មកវិញ បន្ទាប់ពីមានការពិគ្រោះយោបល់ (ជាពិសេសទាក់ទងនឹងបែបបទនៃការបញ្ជូនត្រឡប់ និងការរក្សាទុក) ជាមួយរដ្ឋភាគីដែលពាក់ព័ន្ធនឹង រដ្ឋភាគីដែលជាម្ចាស់នៃវត្ថុទាំងនេះ ពាក់ព័ន្ធនឹងរដ្ឋភាគីនៃនីតិបុគ្គល ឬរូបវន្តបុគ្គលជាម្ចាស់នៃ រូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារទាំងនេះគឺជាជនជាតិ ឬអ្នកស្នាក់នៅ ឬពាក់ព័ន្ធ នឹងរដ្ឋភាគីដែលគេលួចវត្ថុទាំងនោះពីទឹកដីរបស់ខ្លួន ឬទទួលបានដោយខុសច្បាប់។

3. (*a*) ដែលរដ្ឋភាគីត្រូវបានហាមឃាត់ដោយនីតិជាតិនិងអន្តរជាតិមិនឲ្យបញ្ជូនត្រឡប់ ឬទទួលយករូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរទាំងនេះ ឬរដ្ឋភាគីពាក់ព័ន្ធ ព្រមព្រៀងធ្វើដូច្នេះ ដោយអនុលោមតាមកថាខណ្ឌ 3

(*b*) នៃមាត្រាបច្ចុប្បន្ន រដ្ឋភាគីដែលកាន់កាប់រូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរត្រូវបន្តចាត់វិធានការដូចបានពណ៌នានៅក្នុងកថាខណ្ឌ 1 នៃមាត្រាបច្ចុប្បន្ន រូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារទាំងនេះត្រូវតែប្រើក្នុងគោលបំណងសន្តិភាពប៉ុណ្ណោះ។

(*b*) ដែលវាមិនមានលក្ខណៈស្របច្បាប់ដែលរដ្ឋភាគីរក្សាទុករូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរទាំងនោះ រដ្ឋនោះ

ត្រូវតែធានាថាវត្ថុទាំងនោះត្រូវបានទុកដាក់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាននៅក្នុងការឃុំគ្រងរបស់រដ្ឋដែលការកាន់កាប់របស់ទាំងនេះមានភាពស្របច្បាប់ និងដែលបានផ្តល់ការធានាស្របជាមួយសេចក្តីតម្រូវនៃកថាខណ្ឌ 1 នៃមាត្រាបច្ចុប្បន្នដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋនោះក្នុងគោលបំណងប្រែក្លាយវត្ថុទាំងនោះកុំឲ្យមានគ្រោះថ្នាក់ សម្ភារវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារទាំងនេះត្រូវតែប្រើប្រាស់សម្រាប់គោលបំណងសន្តិភាពប៉ុណ្ណោះ។

4. ប្រសិនបើរូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរដែលមានចែងនៅក្នុងកថាខណ្ឌ 1 និង 2 នៃមាត្រាបច្ចុប្បន្នមិនមែនជាកម្មសិទ្ធិរបស់រដ្ឋភាគីណាមួយ ឬរបស់ជនជាតិ ឬអ្នករស់នៅក្នុងរដ្ឋភាគីមួយ ឬមិនត្រូវបានលួច ទទួលបានដោយខុសច្បាប់ពីទឹកដីនៃរដ្ឋភាគី ឬប្រសិនបើមិនមានរដ្ឋណាមានចេតនាចង់ទទួលវត្ថុទាំងនេះដោយអនុលោមតាមកថាខណ្ឌ 3 នៃមាត្រាបច្ចុប្បន្ន សេចក្តីសម្រេចដោយឡែកស្តីពីការសម្រេចទោសរបស់ខ្លួនដោយអនុលោមតាមកថាខណ្ឌ 3 (*b*) នៃមាត្រាបច្ចុប្បន្នត្រូវបានធ្វើឡើងបន្ទាប់ពីមានការពិគ្រោះយោបល់រវាងរដ្ឋពាក់ព័ន្ធ និងអង្គការអន្តរជាតិពាក់ព័ន្ធមួយចំនួន។

5. ចំពោះគោលបំណងនៃកថាខណ្ឌ 1, 2, 3 និង 4 នៃមាត្រាបច្ចុប្បន្ន រដ្ឋភាគីដែលកាន់កាប់រូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរអាចស្នើសុំជំនួយនិងកិច្ចសហការពីរដ្ឋភាគីផ្សេងជាពិសេសរដ្ឋភាគីពាក់ព័ន្ធ និងអង្គការអន្តរជាតិពាក់ព័ន្ធមួយចំនួន ជាពិសេសអង្គការ ថាមពលបរិមាណូអន្តរជាតិ។ រដ្ឋភាគី និងអង្គការអន្តរជាតិពាក់ព័ន្ធត្រូវបាន លើកទឹកចិត្តឲ្យផ្តល់ជំនួយ ដោយអនុលោមតាមកថាខណ្ឌនេះក្នុងកម្រិតអតិបរមាដែលអាចធ្វើទៅបាន។

6. រដ្ឋភាគីដែលពាក់ព័ន្ធក្នុងការសម្រេចទោស ឬរក្សាទុករូបធាតុវិទ្យុសកម្ម ឧបករណ៍ ឬគ្រឿងបរិក្ខារនុយក្លេអ៊ែរដោយអនុលោមតាមមាត្រាបច្ចុប្បន្នត្រូវតែផ្តល់ព័ត៌មានដល់អគ្គនាយកទីភ្នាក់ងារថាមពលបរិមាណូអន្តរជាតិអំពីរបៀបដែលវត្ថុទាំងនេះត្រូវបានបំផ្លាញចោល ឬរក្សាទុក។ អគ្គនាយកទីភ្នាក់ងារថាមពលបរិមាណូអន្តរជាតិត្រូវតែបញ្ជូនព័ត៌មានទៅដល់រដ្ឋភាគីដទៃទៀត។

7. ប្រសិនបើមានការផ្សព្វផ្សាយពាក់ព័ន្ធនឹងបទល្មើសដែលមានចែងនៅក្នុងមាត្រា 2, មិនមានអ្វីមួយនៅក្នុងមាត្រាបច្ចុប្បន្នត្រូវប៉ះពាល់តាមរបៀបណាមួយដែលក្រមនីតិអន្តរជាតិគ្រប់គ្រងលើការទទួលខុសត្រូវចំពោះការខូចខាតដោយនុយក្លេអ៊ែរ ឬក្រមផ្សេងទៀតនៃនីតិអន្តរជាតិ។

**មាត្រា 19**

រដ្ឋភាគីដែលកាត់ទោសជនល្មើសដែលបានចោទប្រកាន់ត្រូវតែបង្ហាញលទ្ធផលចុងក្រោយនៃកិច្ចនីតិវិធីដល់អគ្គលេខាធិការអង្គការសហប្រជាជាតិដែលត្រូវបញ្ជូនព័ត៌មាននេះទៅដល់រដ្ឋភាគីដទៃទៀតដោយអនុលោមទៅតាមនីតិជាតិរបស់ខ្លួន ឬនីតិវិធីដែលត្រូវអនុវត្ត។

**មាត្រា 20**

រដ្ឋភាគីត្រូវធ្វើការពិគ្រោះយោបល់ជាមួយគ្នាដោយផ្ទាល់ ឬតាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយមានជំនួយពី

អង្គការអន្តរជាតិតាមចាំបាច់ ដើម្បីធានាការអនុវត្តអនុសញ្ញានេះយ៉ាងមានប្រសិទ្ធភាព។

**មាត្រា 21**

រដ្ឋភាគីត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមអនុសញ្ញានេះតាមរបៀបមួយដែលមានស័ង្គតភាពជាមួយគោលការណ៍សមភាពអាធិបតេយ្យ និងបូរណភាពទឹកដីនៃរដ្ឋ និងគោលការណ៍មិនជ្រៀតជ្រែកនៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃឡើយ។

**មាត្រា 22**

មិនមានចំណុចណាមួយនៅក្នុងអនុសញ្ញានេះផ្តល់សិទ្ធិឲ្យរដ្ឋភាគីមួយអនុវត្តយុត្តាធិការ និងប្រតិបត្តិមុខងារដែលត្រូវបានរក្សាទុកជាពិសេសសម្រាប់អាជ្ញាធរនៃរដ្ឋភាគីមួយទៀតនោះ តាមនីតិជាតិរបស់ខ្លួននៅក្នុងទឹកដីនៃរដ្ឋភាគីមួយទៀតឡើយ។

**មាត្រា 23**

1. ការខ្វែងគំនិតគ្នាណាមួយរវាងរដ្ឋភាគីពីរ ឬច្រើនទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះដែលមិនអាចដោះស្រាយបានតាមរយៈការចចារនៅក្នុងពេលវេលាសមស្រប ត្រូវតែនាំទៅកាន់តុលាការមជ្ឈត្តវិនិច្ឆ័យតាមសំណើរបស់រដ្ឋភាគីណាមួយ។ នៅក្នុងរយៈពេល៦ ខែ ចាប់ពីកាលបរិច្ឆេទស្នើសុំការសម្រេចពីតុលាការមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើភាគីទាំងឡាយ មិនអាចយល់ព្រមចំពោះការរៀបចំរបស់តុលាការមជ្ឈត្តវិនិច្ឆ័យទេ ភាគីណាមួយក្នុងចំណោមភាគីទាំងនោះអាចនាំយកជម្លោះនេះទៅកាន់តុលាការយុត្តិធម៌អន្តរជាតិដោយអនុវត្តតាមលក្ខខន្តិកៈរបស់តុលាការនេះ។

2. នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ការទទួលយក ឬការអនុម័តចំពោះអនុសញ្ញានេះ ឬការចូលរួមជាមួយ រដ្ឋនីមួយៗប្រកាសថាខ្លួនគិតថាមិនត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយ កថាខណ្ឌ 1 នៃមាត្រាបច្ចុប្បន្ននេះឡើយ។ រដ្ឋភាគីផ្សេងទៀតមិនត្រូវបានចងភ្ជាប់កាតព្វ កិច្ច ដោយកថាខណ្ឌ 1 ស្តីពីរដ្ឋភាគីណាមួយដែលបានកំណត់លក្ខខណ្ឌបែបនេះឡើយ។

3. រដ្ឋភាគីណាមួយដែលបានកំណត់លក្ខខណ្ឌស្របតាមកថាខណ្ឌ 2 នៃមាត្រាថ្មីនេះអាចដកការកំណត់លក្ខខណ្ឌនោះចេញនៅពេលណាក៏បានតាមរយៈការជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ។

**មាត្រា 24**

1. អនុសញ្ញានេះត្រូវបើកចំហសម្រាប់ឲ្យរដ្ឋទាំងអស់ចុះហត្ថលេខាចាប់ពីថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 2005 រហូតដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2006 នៅឯទីស្នាក់ការអង្គការសហប្រជាជាតិនាបុរីញូយ៉ក។

2. អនុសញ្ញានេះស្ថិតនៅក្រោមការផ្តល់សច្ចាប័ន ការទទួលយក ឬយល់ព្រម។ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬយល់ព្រមត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអង្គការ សហប្រជាជាតិ។

3. អនុសញ្ញានេះត្រូវតែបើកចំហចំពោះការចូលរួមដោយរដ្ឋណាមួយ។ លិខិតូបករណ៍នៃចូល រួមត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា 25

1. អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទតម្កល់ទុកនូវលិខិតតូបករណ៍ៗនៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលរួមជាមួយអគ្គ លេខាធិការអង្គការសហប្រជាជាតិលើកទី២២។

2. ចំពោះរដ្ឋនីមួយៗដែលបានផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួមចំពោះអនុសញ្ញានេះបន្ទាប់ពីតម្កល់ទុកនូវលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួមលើកទី២២ នោះអនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី៣០បន្ទាប់ពីតម្កល់ទុកដោយរដ្ឋនៃលិខិតូបករណ៍របស់ខ្លួនអំពីសច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួម។

## មាត្រា 26

1. រដ្ឋភាគីមួយអាចស្នើសុំធ្វើវិសោធនកម្មចំពោះអនុសញ្ញានេះ។ វិសោធនកម្មដែល បានស្នើឡើងត្រូវដាក់ជូនអ្នករក្សាឯកសារតម្កល់ដើម្បីផ្សព្វផ្សាយវិសោធនកម្មនេះដល់រដ្ឋភាគីទាំងអស់ជាបន្ទាន់។

2. ប្រសិនបើរដ្ឋភាគីភាគច្រើនស្នើសុំឲ្យអ្នករក្សាឯកសារតម្កល់កោះប្រជុំដើម្បីពិចារណាលើវិសោធនកម្មដែលបានស្នើឡើង អ្នករក្សាឯកសារតម្កល់ត្រូវអញ្ជើញរដ្ឋភាគីទាំងអស់ចូលរួមកិច្ចប្រជុំនេះដើម្បីចាប់ផ្តើមភ្លាមបន្ទាប់ពីចេញលិខិតអញ្ជើញបានបីខែ។

3. កិច្ចប្រជុំត្រូវខិតខំគ្រប់បែបយ៉ាងដើម្បីធានាថាវិសោធនកម្មត្រូវបានយល់ព្រមតាមកុងសង់ស៊ុស។ ប្រសិនបើមិនអាចមានកុងសង់ស៊ុសទេ វិសោធនកម្មនេះត្រូវទទួលយល់ព្រមដោយរដ្ឋភាគីទាំងអស់ចំនួនពីរភាគបី។ វិសោធនកម្មទាំងឡាយណាដែលបានអនុម័តនៅក្នុង សន្និសីទត្រូវតែផ្សព្វផ្សាយដោយអ្នករក្សាតម្កល់ឯកសារដល់រដ្ឋភាគីទាំងអស់ជាបន្ទាន់។

4. វិសោធនកម្មដែលបានអនុម័តអនុលោមទៅតាមកថាខណ្ឌ 3 នៃមាត្រាបច្ចុប្បន្នត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីនីមួយៗដែលតម្កល់ទុកលិខិតូបករណ៍របស់ខ្លួនអំពីការផ្តល់សច្ចាប័ន ការទទួលយក ការចូលរួម និងការយល់ព្រមចំពោះវិសោធនកម្មនោះនៅថ្ងៃទី៣០បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋភាគីចំនួនពីរភាគបីបានតម្កល់ទុកលិខិតូបករណ៍ពាក់ព័ន្ធរបស់ខ្លួន។ បន្ទាប់ពីនោះមក វិសោធនកម្មនេះត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីណាមួយនៅថ្ងៃទី៣០បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនោះតម្កល់ទុកលិខិតូបករណ៍ពាក់ព័ន្ធរបស់ខ្លួន។

## មាត្រា 27

1. រដ្ឋភាគីណាមួយអាចប្រកាសដកខ្លួនពីអនុសញ្ញានេះតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការអង្គការសហប្រជាជិត។

2. ការប្រកាសដកខ្លួនត្រូវចូលជាធរមានក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានទទួលលិខិតជូនដំណឹងនេះ។

## មាត្រា 28

ច្បាប់ដើមនៃអនុសញ្ញានេះដែលសរសេរជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្សី និង អេស្ប៉ាញគឺមានតម្លៃស្មើគ្នា ត្រូវបានតម្កល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវផ្ញើច្បាប់ចម្លងដែលមានការបញ្ជាក់ទៅកាន់រដ្ឋទាំងអស់។

ដើម្បីជាសាក្ខីភាពចំពោះបញ្ហានេះ ហត្ថលេខាខាងក្រោមដែលបានអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើអនុសញ្ញានេះ ដែលបើកចំហសម្រាប់ចុះហត្ថលេខានៅឯទីស្នាក់ការអង្គការសហប្រជាជាតិនាបុរីញូយ៉ក នៅថ្ងៃទី 14 ខែកញ្ញា ឆ្នាំ 2005។